**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងទាំងអស់មេត្តាជ្រាបថា **ឯកឧត្តម ត្រាំ អ៊ីវតឹក** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អតីតរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាឪពុកបង្កើត លោកជំទាវ តឹក លក្ខិណា អនុរដ្ឋលេខាធិការ បានទទួលមរណភាពនៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ក្នុងជន្មាយុ៧៣ឆ្នាំ ដោយរោគាពាធ។

**ឯកឧត្តម ព្រុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នឹងដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១១:៣០នាទីព្រឹក នៅគេហដ្ឋានលេខ៣៦ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក (មុំក្រោយមន្ទីរពេទ្យខេមា)។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

ថ្ងៃ ពុធ ០៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១ ~~~

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

# សាររំលែកមរណទុក្ខ

**ជូនចំពោះ**

**លោកជំទាវ ឈរ ណារី ត្រាំ អ៊ីវតឹក និងក្រុមគ្រួសារ**

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្តីក្តុកក្តួលរន្ធត់ចិត្តយ៉ាងក្រៃលែង ដោយបានទទួលដំណឹងថា **ឯកឧត្តម ត្រាំ អ៊ីវតឹក** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអតីតរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន អតីតរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលបានទទួលមរណភាពនៅថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១ ក្នុងជន្មាយុ ៧៣ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់ **ឯកឧត្តម ត្រាំ អ៊ីវតឹក** គឺជាការបាត់បង់នូវស្វាមី ឪពុក និងជីតាប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងជាការបាត់បង់ឥស្សរជនជាន់ខ្ពស់មួយរូប ដែលពោរពេញដោយឆន្ទៈ មនសិការការងារក្នុងការបម្រើជាតិ សាសនា ព្រះមហាក្សត្រ ពិសេសការរួមចំណែករបស់ឯកឧត្តមក្នុងការលើកស្ទួយវិស័យសាធារណការនិងដឹកជញ្ជូន ព្រមទាំងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ក្នុងឱកាសប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ជ្រាលជ្រៅ ពោរពេញដោយក្តីសោកស្តាយជាអនេកប្បការជាមួយ លោកជំទាវ បុត្រា បុត្រី ចៅប្រុស ចៅស្រី ព្រមទាំងក្រុមញាតិគ្រួសារ។

ខ្ញុំសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឯកឧត្តម ត្រាំ អ៊ីវតឹក** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ និងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីខ្ញុំ។

ថ្ងៃ ពុធ ០៧ រោច ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ព្រុំ សុខា**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh